ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៣.១៤-០៥៦-០៤៣ ប្រ.ក

# ប្រកាស

## ស្ដីពី

## ការដាក់ឱ្យប្រើវិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង **លោកជំទាវ ជា សិរី** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារវិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System-IPS)" ដែលមាន ម៉ូឌុលបាគង (សេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ) និងម៉ូឌុលទូទាត់សុទ្ធ (សេវាទូទាត់មូលប្បទានបត្រ និងសេវាបណ្ណទូទាត់) ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដាក់ចេញនូវគោលការណ៍ណែនាំដើម្បីគ្រប់គ្រងកិច្ចដំណើរការប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់រួម តួនាទីនិងកាតព្វកិច្ចរបស់គ្រឹះស្ថានសមាជិក និងភាគីពាក់ព័ន្ធតទៅនេះ ហៅថា "គ្រឹះស្ថាន" និងវិធានពាក់ព័ន្ធផ្សេងៗ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថាន ដែលចូលរួមក្នុងដំណើរការប្រព័ន្ធទូទាត់សងប្រាក់រួម។

**ប្រការ ៤.-**

គ្រឹះស្ថានត្រូវគោរពនិងអនុវត្តតាម វិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម យ៉ាងម៉ឺងម៉ាត់។

**ប្រការ ៥.-**

គ្រឹះស្ថាន ដែលមិនអនុវត្តតាមវិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម ត្រូវទទួលទោសតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

អគ្គលេខាធិការ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គពិនិត្យ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២ កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២៦

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល ៖**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

**ចម្លងជូន ៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"